**ការិយាល័យអគ្គនាយក**
440 North Broad Street
Philadelphia, PA 19130

THE SCHOOL DISTRICT OF PHILADELPHIA

**បណ្ឌិត Tony B. Watlington, Ed.D.**
អគ្គនាយក
**ថ្ងៃទី 8 ខែកក្កដា ឆ្នាំ 2024**

គ្រួសារនៃមណ្ឌលសិក្សាទីក្រុង Philadelphia ជាទីគោរព!

មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia មានសេចក្តីរំភើបក្នុងការប្រកាសអំពី ***ការប្រារព្ធពិធីត្រឡប់ចូលសិក្សាវិញ និងដំណើរទស្សនកិច្ចតាមឡានក្រុងប្រចាំឆ្នាំលើកទី 4***! យើងទន្ទឹងរង់ចាំដើម្បីចាប់ផ្តើម និងជួយដល់ក្រុមគ្រួសារដើម្បីត្រៀមខ្លួនសម្រាប់ថ្ងៃដំបូងនៃឆ្នាំសិក្សា 2024-2025 – នៅថ្ងៃចន្ទ ទី 26 ខែសីហា ឆ្នាំ 2024។

ដូចឆ្នាំមុនៗដែរ ដំណើរទស្សនកិច្ចនេះដំណើរការដោយមូលនិធិ Blue Cross Foundation ហើយនាំមកជូននូវព័ត៌មាន និងសេវាកម្មសម្រាប់ការត្រឡប់ចូលសិក្សាវិញសំខាន់ៗ ដែលត្រឹមត្រូវសម្រាប់សង្កាត់របស់អ្នក។ ចាប់ពីថ្ងៃទី 29 ខែកក្កដាដល់ថ្ងៃទី 17 ខែសីហា ឡានក្រុងនឹងធ្វើដំណើរឆ្លងកាត់ទីក្រុង Philly ដោយផ្តល់នូវកម្មវិធី Mega-Events ចំនួន 7 ដែលពោរពេញទៅដោយភាពសប្បាយរីករាយក្រោមកិច្ចសហការឧបត្ថម្ភដោយដៃគូជាច្រើនរួមមាន Radio One, Office Depot និង Roosevelt Mall ក៏ដូចជាដៃគូថ្មីនៅឆ្នាំនេះ គឺ Fashion District Philadelphia! នៅក្នុងព្រឹត្តិការណ៍ទាំងនេះ អ្នកអាច៖

- រីករាយជាមួយអាហារសម្រន់ និងអាហារក្លាសេនានា
- ចូលរួមក្នុងហ្គេមសប្បាយៗ និងក្នុងឆ្នោតផ្សងសំណាង
- ជជែកជាមួយទូតសុឆន្ទៈរបស់ក្រុមការងារ Street Team របស់យើងដើម្បីទទួលបានព័ត៌មានត្រឡប់ចូលសិក្សាវិញ ដែលអ្នកត្រូវការ
- ចុះឈ្មោះកូនរបស់អ្នកសម្រាប់ថ្នាក់មុនមត្តេយ្យសិក្សារហូតដល់ថ្នាក់ទី 12
- ចូលរួមក្នុងសកម្មភាពអប់រំនានា
- ចុះឈ្មោះបង្កើតគណនីក្នុងផតថលសម្រាប់មាតាបិតា
- ***ទទួលបានកាបូបស្ពាយ*** និងសម្ភារសិក្សាដោយឥតគិតថ្លៃ
- ទទួលបានព័ត៌មានសំខាន់ៗពីអង្គការដៃគូរបស់យើងរាប់សិបមកពីជុំវិញទីក្រុង
- ឱ្យកូនរបស់អ្នកទទួលបានការចាក់ថ្នាំបង្ការ និងការពិនិត្យកាយសម្បទានៅសាលារៀនដោយ***ឥតគិតថ្លៃ*** ដែលត្រូវការដើម្បីទៅសាលារៀន និងច្រើនទៀត។

**ស្វែងរកកាលវិភាគដំណើរទស្សនកិច្ចតាមឡានក្រុងពេញលេញ ព័ត៌មានថ្មីៗចុងក្រោយបំផុតអំពីការត្រឡប់ចូលសិក្សាវិញ ឱកាសចាក់ថ្នាំបង្ការ និងព័ត៌មានសំខាន់ៗផ្សេងទៀតនៅ** **philasd.org/ringthebell** ឬដោយការទូរសព្ទទៅលេខ 215-400-4000។ ខ្ញុំសង្ឃឹមថានឹងជួបអ្នកនៅក្នុងចំណតឈប់ក្នុងដំណើរទស្សនកិច្ចមួយក្នុងចំណោមឈប់ចំណតទាំងអស់ ហើយទន្ទឹងរង់ចាំក្នុងការចុចកណ្តឹងបើកឆ្នាំសិក្សាថ្មីក្នុងរដូវស្លឹកឈើជ្រុះនេះ។

ដើម្បីភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយក
មណ្ឌលសិក្សាធិការទីក្រុង Philadelphia